KH

# គោលការណ៍ណែនាំអំពីសកម្មភាពដៃគូអាជីវកម្ម

## I. សំណើសុំ និងគោលបំណងនៃគោលការណ៍ណែនាំ

ក្រុមហ៊ុន SEVEN&i Group បានព្យាយាមខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីប្រែក្លាយខ្លួនជាក្រុមហ៊ុនស្មោះត្រង់ គួរជាទីទុកចិត្តពីសំណាក់ភាគីពាក់ព័ន្ធដែលគាំទ្រសកម្មភាពសាជីវកម្មរបស់យើង ដែលមានដូចជា "អតិថិជន ដៃគូអាជីវកម្ម ភាគហ៊ុននិក សហគមន៍មូលដ្ឋាន និងនិយោជិត។" ប្រការនេះ ត្រូវបានកំណត់ជា "ជំនឿសាជីវកម្ម" របស់យើងចាប់តាំងពីពេលបង្កើតមកម្ល៉េះ ហើយយើងមានគោលបំណងចង់ឲ្យនិយោជិតទាំងអស់យល់ដឹងស៊ីជម្រៅអំពី "គោលការណ៍ណែនាំអំពីសកម្មភាពដៃគូអាជីវកម្មរបស់ក្រុមហ៊ុន SEVEN&i Group"។

បច្ចុប្បន្ន ដោយសារតែសកលភាវូបនីយកម្មសេដ្ឋកិច្ច និងពិពិធកម្មនៃតម្រូវការរបស់ភាគីពាក់ព័ន្ធ សាជីវកម្មនានាកំពុងតែត្រូវបានទាមទារកាន់តែខ្លាំងឡើង ឲ្យក្លាយជាផ្នែកមួយនៃទំនួលខុសត្រូវសង្គម ដោយចូលរួមធ្វើអាជីវកម្មប្រកបដោយទំនួលខុសត្រូវដើម្បីធានាឲ្យបាននូវអនុលោមភាពផ្លូវច្បាប់ និងបទប្បញ្ញត្តិ លើកកម្ពស់ការអភិរក្សបរិស្ថាន និងពិចារណាអំពីលក្ខខណ្ឌការងារនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ទាំងមូល រួមទាំងដៃគូអាជីវកម្មពាក់ព័ន្ធនឹងផលិតផល និងសេវាកម្ម ដែលគ្រប់គ្រងផ្ទាល់ដោយសាជីវកម្ម។

ដោយសារតែកាលៈទេសៈនេះហើយ ទើបនៅក្នុងឆ្នាំ2007 ក្រុមហ៊ុនបានបង្កើត "គោលការណ៍ណែនាំអំពីសកម្មភាពដៃគូអាជីវកម្ម SEVEN&i HLDGS. "(គោលការណ៍ណែនាំ)" នេះឡើង និងបានធ្វើការកែសម្រួលឡើងវិញនៅក្នុងឆ្នាំ2017។ ក្រុមហ៊ុនយល់ឃើញថាតាមរយៈការយល់ដឹង និងការអនុវត្តតាមគោលការណ៍ណែនាំនេះ ដោយដៃគូអាជីវកម្មផ្ទាល់នៃក្រុមហ៊ុននីមួយៗ នៅក្នុងគ្រុបក្រុមហ៊ុន នឹងមិនត្រឹមតែធ្វើឲ្យមានស្ថិរភាពនៃសកម្មភាពអាជីវកម្មសម្រាប់ទាំងដៃគូអាជីវកម្ម និងក្រុមហ៊ុននីមួយៗនៅក្នុងគ្រុបក្រុមហ៊ុន ដូចជាការកាត់បន្ថយហានិភ័យការផ្អាកអាជីវកម្មដោយសារការរំលោភទៅនឹងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ និងការជៀសវាងពីការធ្វើពហិការរបស់អតិថិជន ដែលកើតចេញពីឧប្បត្តិហេតុទាំងអស់នោះប៉ុណ្ណោះទេ ប៉ុន្តែកិច្ចការនេះក៏នឹងជួយឲ្យរក្សាបាន និងបង្កើនសុវត្ថិភាព និងគុណភាពផលិតផលទៀតផង។ លើសពីនេះទៅទៀត តាមរយៈការយល់ដឹង និងការអនុវត្តតាមឥរិយាបថ និងគោលបំណងនៃគោលការណ៍ណែនាំរបស់គ្រុបក្រុមហ៊ុន ទាំងពីសំណាក់ដៃគូអាជីវកម្មផ្ទាល់ និងអ្នកផ្គត់ផ្គង់ដែលដៃគូអាជីវកម្មបានធ្វើលទ្ធកម្មផលិតផល និងវត្ថុធាតុដើមពីពួកគេ ក្រោមការគ្រប់គ្រងរបស់គ្រុបក្រុមហ៊ុននោះ យើងជឿជាក់ថាយើងនឹងទទួលបាននូវទំនុកចិត្តកាន់តែច្រើនបន្ថែមទៀតពីសំណាក់ភាគីពាក់ព័ន្ធ ហេតុដូច្នេះហើយ យើងនឹងអាចចូលរួមក្នុងការសម្រេចបាននូវគោលដៅនៃសង្គមមួយប្រកបដោយចីរភាព សហអត្ថិភាព និងវិបុលភាពសម្រាប់យើងទាំងអស់គ្នា។

តាមរយៈការជឿជាក់នេះ យើងសូមស្នើសុំឲ្យដៃគូអាជីកម្មទាំងអស់បង្កើតប្រព័ន្ធដើម្បីធានាឲ្យបាននូវអនុលោមភាពទៅនឹងគោលការណ៍ណែនាំនេះនៅក្នុងក្រុមហ៊ុនរបស់ខ្លួន និងដោយអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុនអ្នកផងដែរ។

យើងសូមស្នើសុំឲ្យមានកិច្ចសហការឲ្យកាន់តែស្អិតរមួតបន្ថែមទៀតពីសំណាក់ដៃគូអាជីវកម្មរបស់យើង។

ធ្វើនៅខែមេសា ឆ្នាំ2017
Ryuichi Isaka
ក្រុមហ៊ុន SEVEN&i HLDGS. Co., Ltd
ប្រធាន និងប្រធានតំណាង

KH

## II. គោលការណ៍ណែនាំអំពីសកម្មភាពដៃគូអាជីវកម្ម ក្រុមហ៊ុន SEVEN&i Group

ក្រុមហុន SEVEN&i Group សូមស្នើសុំថា មិនត្រឹមតែដៃគូអាជីកម្មផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែអ្នកផ្គត់ផ្គង់ ដែលដៃគូអាជីវកម្មបានធ្វើលទ្ធកម្មផលិតផលពីពួកគេ ក្រោមការគ្រប់គ្រងក្នុងគ្រុបក្រុមហ៊ុន SEVEN&i Group ក៏គប្បីត្រូវយល់ដឹង ទទួលការផ្សព្វផ្សាយ និងអនុវត្តវិធានការនានាដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចខាងក្រោម។

ប្រតិបត្តិការអាជីវកម្មអាចនឹងត្រូវផ្អាកជាបណ្តោះអាសន្ន ឬកិច្ចសន្យាអាចនឹងត្រូវបញ្ចប់ ប្រសិនបើ រកឃើញថាមានការប្រព្រឹត្តរំលោភបំពានណាមួយទៅនឹងគោលការណ៍។

### 1. អនុលោមភាពផ្លូវច្បាប់

1. ត្រូវមានអនុលោមភាពទៅនឹងទាំងបញ្ញត្តិ និងស្មារតីនៃច្បាប់ពាក់ព័ន្ធនៅក្នុងប្រទេស និងក្នុងតំបន់នីមួយៗ ក៏ដូចជាវិធានអន្តរជាតិដែលពាក់ព័ន្ធផងដែរ។
2. ការបង្កើតគោលនយោបាយ ការកសាងប្រព័ន្ធ ការអនុវត្តការបណ្តុះបណ្តាល និងការបង្កើតប្រព័ន្ធរាយការណ៍ផ្ទៃក្នុង -ល- សម្រាប់គោលបំណងអនុលោមភាពផ្លូវច្បាប់។

### 2. ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ

**ត្រូវតែគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលម្នាក់ៗដែលពាក់ព័ន្ធក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។**

1. គប្បីពិចារណាអំពីការបង្កើតកន្លែងធ្វើការដែលបុគ្គលផ្សេងៗគ្រប់រូបនៅទីនោះស្គាល់សក្តានុពលពេញលេញរបស់ខ្លួន។
2. មិនត្រូវប្រើប្រាស់ពលកម្មកុមារ ដែលត្រូវបានហាមឃាត់នៅក្រោមសន្ធិសញ្ញារបស់អង្គការពលកម្មអន្តរជាតិ (ILO) និងច្បាប់ពាក់ព័ន្ធនានាក្នុងប្រទេស។
3. កម្មករនិយោជិតទាំងអស់ត្រូវចូលរួមធ្វើការងាររបស់ខ្លួនទៅតាមឆន្ទៈសេរីភាពរបស់ពួកគេ និងហាមមិនឲ្យមានពលកម្មការងារដែលមានការបង្ខិតបង្ខំឡើយ។ មិនត្រូវមានការទាមទារដោយមិនសមហេតុផលឲ្យប្រគល់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ឬបង់ប្រាក់តម្កល់ពីកម្មករនិយោជិតឡើយ។
4. ហាមដាច់ខាតមិនឲ្យមានការរើសអើងពូជសាសន៍ សញ្ជាតិ សាសនា ភេទ អាយុ ពិការភាព ទំនោរផ្លូវភេទ* អត្តសញ្ញាណយេនឌ័រ* សកម្មភាពសហជីពការងារ ឬសកម្មភាពនយោបាយឡើយ និងត្រូវទទួលបានឱកាសស្មើៗគ្នានៅក្នុងការបំពេញការងារ ការទទួលសំណង ការដំឡើងឋានៈ ការផ្លាស់ប្តូរទីតាំងការងារ ការបណ្តុះបណ្តាល ការបញ្ឈប់ពីការងារ ឬការលាឈប់ពីការងារ។
5. ហាមមិនឲ្យមានការធ្វើទារុណកម្មលើខ្លួនប្រាណ ឬការរំលោភបំពានរូបរាង្គកាយ ផ្លូវចិត្ត ឬការបៀតបៀនផ្លូវភេទឡើយ។

| | |
|---|---|
| * ទំនោរផ្លូវភេទ៖ | និន្នការផ្លូវភេទរបស់មនុស្សជាមូលដ្ឋាន ពាក់ព័ន្ធលើថាតើភេទណា ដែលបុគ្គលស្រលាញ់ ចាប់អារម្មណ៍ ឬមានចំណាប់ផ្លូវភេទដោយផ្ទាល់។ |
| * អត្តសញ្ញាណយេនឌ័រ៖ | ទស្សនៈ ឬអារម្មណ៍របស់នរណាម្នាក់ទៅលើយេនឌ័រណាមួយ ដែលបុគ្គលម្នាក់មាន។ |

## 3. បរិយាកាស និងការបំពេញការងារ

**បុគ្គលទាំងអស់ដែលចូលរួមនៅក្នុងសកម្មភាពអាជីវកម្ម ត្រូវជ្រើសរើសឲ្យធ្វើការងារក្នុងលក្ខណៈ សមស្រប នៅក្នុងបរិយាកាសការងារដែលមានអនាម័យ អាចបំពេញមុខងារបាន និងមានមេត្រីភាពសម្រាប់កម្មករនិយោជិត ដោយពិចារណាលើសុវត្ថិភាព និងសុខភាព។**

1. នៅពេលចូលធ្វើការងារ ត្រូវមានការចុះកិច្ចសន្យាការងារសមស្របមួយ ជាមួយនឹងកម្មករនិយោជិតនោះ ស្របទៅតាមច្បាប់ពាក់ព័ន្ធនានានៅក្នុងប្រទេស។
2. ម៉ោងធ្វើការត្រូវអនុលោមតាមច្បាប់ពាក់ព័ន្ធនានានៅក្នុងប្រទេស។ កម្មករនិយោជិត ត្រូវទទួលបានម៉ោងសម្រាក និងថ្ងៃឈប់សម្រាកសមស្រប ទៅតាមអ្វីដែលបានចែង និងអនុលោមតាមច្បាប់ពាក់ព័ន្ធនានានៅក្នុងប្រទេស។
3. កម្មករនិយោជិតត្រូវទទួលបានប្រាក់ឈ្នួលអប្បបរមា ឬច្រើនជាងនេះ ដោយអនុលោមតាមច្បាប់ពាក់ព័ន្ធនានានៅក្នុងប្រទេស។ កម្មករនិយោជិត ត្រូវទទួលបានការតបស្នងទៅតាម ឬលើសពីអត្រាប្រាក់ឈ្នួលផ្លូវច្បាប់សម្រាប់ការធ្វើការងារបន្ថែមម៉ោងរបស់ពួកគេ។
4. ការងារបន្ថែមម៉ោង មិនត្រូវតម្រូវឲ្យធ្វើដោយគ្មានការយល់ព្រមពីកម្មករនិយោជិតជាមុនឡើយ។
5. មិនត្រូវមានការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងនៅពេលយប់/ឬនៅក្នុងលក្ខខណ្ឌការងារគ្រោះថ្នាក់ឡើយ។
6. ត្រូវមានការធានាថាអគារដែលបំពេញការងារមានភាពរឹងមាំគ្រប់គ្រាន់ ដើម្បីធានានូវសុវត្ថិភាពរបស់កម្មករនិយោជិត និងត្រូវទទួលបានការអនុញ្ញាត និងការឯកភាពក្រោមច្បាប់ពាក់ព័ន្ធនឹងស្តង់ដារអគារក្នុងមូលដ្ឋាន ហើយអគារត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ និងឆ្លងផុតការត្រួតពិនិត្យ។
7. ត្រូវមានច្រកសង្គ្រោះបន្ទាន់ ច្រកជម្លៀស និងសញ្ញាផ្សេងៗនៅកន្លែងការងារ និងត្រូវមានការត្រួតពិនិត្យតាមពេលកំណត់ ព្រមទាំងការបណ្តុះបណ្តាលអំពីការជម្លៀសខ្លួនផងដែរ។
8. ត្រូវមានបង្គន់អនាម័យ និងទឹកពិសារសម្រាប់កម្មករនិយោជិត និងមិនត្រូវមានការរឹតត្បិតការប្រើប្រាស់បង្គន់អនាម័យ និងទឹកពិសារនៅអំឡុងម៉ោងធ្វើការរបស់ពួកគេជាដាច់ខាត។
9. កម្មករនិយោជិតត្រូវតែទទួលបានសម្ភារចំបាច់សម្រាប់ការងាររបស់ពួកគេ រួមទាំងឧបករណ៍ ការពារខ្លួន ស្លាកសញ្ញាព័ត៌មាន និងការបណ្តុះបណ្តាល។
10. ប្រសិនបើមានការផ្តល់កន្លែងស្នាក់នៅសម្រាប់កម្មករនយោជិត នៅទីនោះត្រូវមានបរិយាកាស រស់នៅដែលមានអនាម័យ និងមានសុវត្ថិភាព។
11. ត្រូវអនុវត្តតាមច្បាប់ពាក់ព័ន្ធនឹងអត្ថប្រយោជន៍កម្មករនយោជិត ហើយត្រូវពិចារណាអំពីការបង្កើតកម្មវិធីអត្ថប្រយោជន៍កម្មករនិយោជិត ដែលអាចឲ្យពួកគេធ្វើការដោយគ្មានការព្រួយបារម្ភអំពីបញ្ហាផ្លូវច្បាប់។
12. ត្រូវបង្កើតឲ្យមានទំនាក់ទំនងគ្រប់គ្រងការងារដែលមានភាពល្អប្រសើរតាមរយៈកិច្ចសន្ទនា និងការពិភាក្សាជាមួយនឹងកម្មករនិយោជិត ឬតំណាងរបស់ពួកគេ។ ត្រូវមានការគោរពចំពោះសិទ្ធិសេរីភាពក្នុងការចូលរួមសមាគមរបស់កម្មករនិយោជិត។

## 4. ការការពារបរិស្ថានពិភពលោក

**សកម្មភាពអជីវកម្ម ត្រូវអនុវត្តដោយមានការពិចារណាទៅលើបរិស្ថានពិភពលោកនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដូចជានៅក្នុងការធ្វើលទ្ធកម្មវត្ថុធាតុដើម ការផលិត និងការផ្គត់ផ្គង់នៅក្នុងលក្ខណៈ ដែលចូលរួមចំណែកទៅក្នុងការអភិវឌ្ឍសង្គមប្រកបដោយចីរភាព។**

1. ត្រូវអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ និងស្តីពីបរិស្ថាន។
2. ហាមមិនឲ្យមានការប្រើប្រាស់សារធាតុគីមី ដែលបានហាមឃាត់ដោយសន្ធិសញ្ញាអន្តរជាតិ ឬច្បាប់ក្នុងប្រទេស ឬដោយក្រុមហ៊ុនប្រតិបត្តិការរបស់ក្រុមហ៊ុន SEVEN&i Group។ កាកសំណល់ ផ្សេង និងទឹកសំណល់ ត្រូវគ្រប់គ្រងឲ្យបានត្រឹមត្រូវដើម្បីបង្ការពីការបំពុលបរិស្ថាន។
3. ត្រូវមានការយល់ដឹងត្រឹមត្រូវអំពីឥទ្ធិពលដែលអាជីវកម្មមានលើបរិស្ថាន។
4. ត្រូវចាត់ទុកការសន្សំសំចៃថាមពលជាវិធានការមួយក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងត្រូវកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
5. ត្រូវធ្វើលទ្ធកម្មវត្ថុធាតុដើមក្នុងលក្ខណៈដែលមាននិរន្តរភាពដើម្បីបង្ការការបាត់បង់ ធនធាន និងដោយពិចារណាទៅលើបរិស្ថានផលិតកម្មផងដែរ។
6. ត្រូវទទួលស្គាល់អំពីសារសំខាន់នៃជីវចម្រុះ និងអភិរក្សជីវចម្រុះ។

## 5. ទំនាក់ទំនងជាមួយសហគមន៍ជាតិ និងអន្តរជាតិ

**ការគោរពតាមវប្បធម៌ និងទំនៀមទំលាប់ -ល- របស់ប្រទេស និងតំបន់ ដែលអាជីវកម្មដំណើរការ និងបង្កើតកិច្ចសហការដើម្បីការអភិវឌ្ឍសង្គមប្រកបដោយចីរភាព។**

1. ការយល់ដឹងអំពីបញ្ហាសង្គមផ្សេងៗពាក់ព័ន្ធនឹងសហគមន៍ជាតិ និងអន្តរជាតិតាមរយៈកិច្ចសន្ទនា និងការចូលរួមដោះស្រាយបញ្ហាទាំងនេះ តាមរយៈកិច្ចសហប្រតិបត្តិការ កិច្ចសហការ និងអាជីវកម្មរវាងគ្នានឹងគ្នា។
2. មិនត្រូវមានការចូលរួមជាមួយនឹងក្រុមឧក្រិដ្ឋជនដែលមានការរៀបចំ សមាជិកក្រុមឧក្រិដ្ឋជនដែលមានការរៀបចំ ក្រុមហ៊ុន និងក្រុមឧក្រិដ្ឋកម្មដែលមានការរៀបចំ ក្រុមទុច្ចរិត (sokaiya) ក្រុមដែលចូលរួមក្នុងសកម្មភាពឧក្រិដ្ឋកម្មដែលធ្វើពុតជាធ្វើយុទ្ធនាការសង្គម ឬសកម្មភាពនយោបាយ ក្រុមឧក្រិដ្ឋកម្មដែលជំនាញលើឧក្រិដ្ឋកម្មករណីកម្មសិទ្ធិបញ្ញា ឬកងកម្លាំងប្រឆាំងនឹងសង្គមផ្សេងឡើយ។

## 6. ការគ្រប់គ្រងព័ត៌មាន

**ការរក្សាឲ្យបានសមស្របនូវព័ត៌មានដែលទទួលបានក្នុងអំឡុងពេលប្រតិបត្តិការអជីវកម្ម។**

1. ដើម្បីបង្ការពីការលេចធ្លាយ ឬការលួចព័ត៌មាន ត្រូវមានការគ្រប់គ្រងតឹងរឹងចំពោះព័ត៌មាន និងទិន្នន័យផ្ទាល់ខ្លួនដែលទទួលបានក្នុងអំឡុងពេលប្រតិបត្តិការអជីវកម្ម។
2. ព័ត៌មានទាំងអស់នេះ ត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងសកម្មភាពអាជីវកម្មតែប៉ុណ្ណោះ។ ហេតុដូច្នេះ មិនត្រូវបានប្រើប្រាស់ព័ត៌មានទាំងអស់នេះសម្រាប់គោលបំណងអាជីវកម្មផ្សេងទៀត ឬឯកជន ឬដោយភាគីផ្សេងទៀតឡើយ។

## 7. ការធានាសុវត្ថិភាពផលិតផល

**ដើម្បីផ្តល់ទំនិញដែលមានសុវត្ថិភាព និងគួរជាទីទុកចិត្តដល់អ្នកប្រើប្រាស់ចុងក្រោយ ត្រូវអនុលោមទៅតាមស្តង់ដារគុណភាពនៃក្រុមហ៊ុនប្រតិបត្តិការពាក់ព័ន្ធរបស់ក្រុមហ៊ុន SEVEN&i Group និង ចំណុចដែលមានចែងដូចខាងក្រោម៖**

1. ត្រូវអនុវត្តតាមស្តង់ដារផ្លូវច្បាប់ ដែលមានចែងទាំងក្នុងប្រទេសផលិត និងប្រទេសលក់។
2. ព័ត៌មានចាំបាច់ពាក់ព័ន្ធនឹងផលិតផល និងសេវា ត្រូវផ្សព្វផ្សាយឲ្យបានទាន់ពេលវេលា និងត្រឹមត្រូវ។
3. ដោយមានការទទួលស្គាល់ថាអាចមានគុណវិបត្តិចំពោះអតិថិជនរបស់យើង (អ្នកប្រើប្រាស់ចុងក្រោយ) ព័ត៌មានពាក់ព័ន្ធ នឹងត្រូវផ្សព្វផ្សាយឲ្យបានទាន់ពេលវេលា និងត្រឹមត្រូវ ដើម្បីបំបាត់នូវដើមហេតុ ឬបង្ការពីការបង្កឲ្យកើតមាននូវគុណវិបត្តិ ព្រមទាំងត្រូវអនុវត្តវិធានការបង្ការការរីកលដាលនៃគុណវិបត្តិក្នុងអាទិភាពខ្ពស់បំផុតផងដែរ។
4. អនុវត្តសកម្មភាពលទ្ធកម្មដោយពិចារណាលើផលប៉ះពាល់ចំពោះសហគមន៍ក្នុងស្រុកពីការប្រើប្រាស់វត្ថុធាតុដើម ដែលអាចនឹងបង្កឲ្យមានបញ្ហាសង្គម ដូចជាបញ្ហាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងបរិស្ថាន និងការអនុវត្តវិធានការដើម្បីបញ្ចៀសការប្រើប្រាស់វត្ថុធាតុដើមនោះនៅករណីមានការព្រួយបារម្ភ។

## 8. ប្រតិបត្តិការអាជីវកម្មដោយភាពយុត្តិធម៌

**ប្រតិបត្តិការអាជីវកម្មគួរអនុវត្តឡើងក្នុងបរិយាកាសយុត្តិធម៌ មានតម្លាភាព សមស្រប និងមានការប្រកួតប្រជែងដោយសេរី។ ត្រូវរក្សាឲ្យបាននូវទំនាក់ទំនងសមស្រប និងរឹងមាំជាមួយនឹងអង្គភាពនយោបាយ និងទីភ្នាក់ងាររដ្ឋាភិបាល។**

1. ត្រូវគោរពតាមគោលការណ៍ប្រកួតប្រជែងដោយសេរី និងយុត្តិធម៌ និងត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដូចជាច្បាប់ប្រឆាំងទៅនឹងភាពផ្តាច់មុខ និងវិធាន ផ្ទៃក្នុងផ្សេងៗទៀត។
2. ប្រតិបត្តិការអាជីវកម្មត្រូវធ្វើឡើងទៅតាមខចែង និងលក្ខខណ្ឌសមស្រប ដោយស្របតាមទម្លាប់អាជីវកម្មល្អប្រសើរ និងមិនត្រូវទទួលយកគុណប្រយោជន៍ អត្ថប្រយោជន៍ផ្ទាល់ខ្លួនឡើយ។
3. ដៃគូពាណិជ្ជកម្មរបស់យើងត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ និងរក្សាទំនាក់ទំនងល្អ និងសមស្របជាមួយនឹងអង្គភាពនយោបាយ និងទីភ្នាក់ងាររដ្ឋាភិបាល នៅពេលផ្តល់វិភាគទាននយោបាយ អំណោយ អត្ថប្រយោជន៍ជាការកម្សាន្ត ឬថវិកាដល់មន្ត្រី រដ្ឋាភិបាលបរទេស ឬបុគ្គលដែលមានលក្ខណៈស្រដៀងនេះ។

## 9. ការការពារកម្មសិទ្ធិបញ្ញា

1. ការការពារសិទ្ធិកម្មសិទ្ធិបញ្ញាដែលកាន់កាប់ ឬជាកម្មសិទ្ធិរបស់ក្រុមហ៊ុនខ្លួន និងបម្រុងប្រយ័ត្នក្នុងការការពារការរំលោភដោយភាគីទីបីណាមួយ។
2. មិនត្រូវចូលរួមក្នុងការរំលោភទៅលើសិទ្ធិណាមួយ ឧទាហរណ៍ដូចជា ការទិញ ឬការប្រើប្រាស់កម្មសិទ្ធិបញ្ញាដោយគ្មានការអនុញ្ញាត ដូចជាប៉ាតង់របស់ភាគីទីបី វិញ្ញាបនបត្រម៉ូដែលការបង្កើតថ្មី គំនូរ ពាណិជ្ជសញ្ញា និងការណ៍សម្ងាត់ពាណិជ្ជកម្ម ការប្រើប្រាស់កម្មវិធីផ្នែកទន់មិនមានការអនុញ្ញាត និងការថតចម្លងសៀវភៅដោយគ្មានការអនុញ្ញាត ។ល។

### 10. ការគ្រប់គ្រងប្រតិបត្តិការនាំចេញ និងនាំចូល

1. ត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងការនាំចេញ និងការនាំចូលផលិតផល និងវត្ថុធាតុដើម-ល-។
2. ហាមមិនឲ្យមានទំនាក់ទំនងជាមួយនឹងប្រទេស និងតំបន់ អង្គភាព ឬបុគ្គលណាមួយ ដែលរងទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្មអន្តរជាតិ ពាក់ព័ន្ធនឹងការផ្តល់មូលនិធិ និងទំនិញសម្រាប់ផលិតផល និងវត្ថុធាតុដើម ឬប្រាក់ឈ្នួល ដែលត្រូវបានចាត់ទុកថាជាតម្លៃតបស្នងសម្រាប់កម្លាំងពលកម្មឡើយ។

### 11. ការអភិវឌ្ឍទៅក្នុងសង្វាក់ផ្គត់ផ្គង់

ដៃគូអាជីវកម្មរបស់យើងត្រូវខិតខំធ្វើយ៉ាងណាឲ្យភាគីផ្គត់ផ្គង់របស់ដៃគូអាជីវកម្មយល់ដឹង និងអនុវត្តតាមគោលការណ៍ណែនាំនេះ និងអនុវត្តវិធានការតាមដាន និងកែតម្រូវតាមភាពចាំបាច់ពីពេលទៅពេលមួយ។

### 12. ការតាមដាន

## ចូលរួមសហការអនុវត្តគោលការណ៍ណែនាំ

1. ត្រូវមានកិច្ចសហប្រតិបត្តិការនៅក្នុងកម្មវិធីតាមដាន ដែលបានបង្កើតឡើងដើម្បីធ្វើការផ្ទៀងផ្ទាត់អនុលោមភាពរបស់ពួកគេទៅនឹងគោលការណ៍ណែនាំ ប្រសិនបើមានការស្នើសុំ។
2. ការរៀបចំ និងការរក្សាឯកសារភស្តុតាង និងកំណត់ត្រាការអនុវត្តការងារ ដែលគាំទ្រថាការអនុវត្តរបស់ខ្លួនអនុលោមទៅនឹងគោលការណ៍ណែនាំ។ ប្រសិនបើមានការស្នើសុំ ត្រូវបង្ហាញឯកសារដែលបានចងក្រងទុកដូចបានរៀបរាប់។
3. ត្រូវចាត់វិធានការកែតម្រូវការមិនអនុវត្តតាមគោលការណ៍ណែនាំដែលបានរកឃើញ ប្រសិនបើមាន។

## III. ប្រព្រឹត្តកម្មនៃគោលការណ៍ណែនាំ

ប្រសិនបើមានការបញ្ជាក់លើការប្រព្រឹត្តរំលោភបំពានណាមួយទៅលើគោលការណ៍ណែនាំនេះ នោះនឹងអាចឈានទៅដល់ការផ្អាកអាជីវកម្ម ឬការបញ្ចប់កិច្ចសន្យា។

ក្រុមហ៊ុន SEVEN&i Group មានគោលបំណងពង្រឹងគុណតម្លៃសាជីវកម្មទាំងរបស់ដៃគូអាជីវកម្ម ហើយ ក្រុមហ៊ុន SEVEN&i Group ខ្លួនឯង តាមរយៈការយល់អំពីគោលបំណង និងការអនុវត្តតាមគោលការណ៍ណែនាំនេះ ហេតុដូច្នេះ យើងខ្ញុំសូមថ្លែងអំណរគុណសម្រាប់ការយោគយល់ និងកិច្ចសហប្រតិបត្តិការរបស់អស់លោក/លោកស្រី។

ធ្វើនៅខែមីនា ឆ្នាំ2007
បានកែសម្រួលនៅខែមេសា ឆ្នាំ2017